# រដ្ឋសភា និងព្រឹទ្ធសភា

## ក) រដ្ឋសភា



រដ្ឋសភា (The National Assembly) **គឺជាស្ថាប័នប្រជាធិបតេយ្យខ្ពស់បំផុត**[១១] ដែលតំណាងឱ្យប្រជាពលរដ្ឋកម្ពុជាទាំងមូល ។

រដ្ឋសភាបាន**បង្កើតនូវក្បួនច្បាប់**សម្រាប់សង្គមកម្ពុជា ។ ព្រោះហេតុដូច្នេះ រដ្ឋសភាត្រូវយកមកពិចារណានូវគោលជំហររបស់សមាជិកសង្គមទាំងអស់ នៅពេលដែលខ្លួនធ្វើច្បាប់ដែលអាចប៉ះពាល់ដល់ពួកគេ ។ សូម្បីតែសមាជិកសង្គម មិនត្រូវបានតំណាងដោយសមាជិកសភាភាគច្រើនក៏ដោយ ក៏រដ្ឋសភា ត្រូវថ្លឹងថ្លែង និងធ្វើឱ្យសិទ្ធិមនុស្សរបស់ពួកគេមានតុល្យភាពដែរ ។

រដ្ឋសភាត្រូវតែ**ជ្រើសតាំង និងគ្រប់គ្រងអំណាចនីតិប្រតិបត្តិ** ដោយពិនិត្យមើលថា តើអង្គនីតិប្រតិបត្តិអនុវត្តច្បាប់បានល្អ ឬក៏អត់ ហើយរដ្ឋសភាក៏អាចបណ្តេញរដ្ឋមន្ត្រីម្នាក់ នាយករដ្ឋមន្ត្រី ឬក៏រដ្ឋាភិបាលទាំងមូលចេញពីតំណែងផងដែរ ។

ដើម្បីឱ្យការងាររបស់រដ្ឋសភាមានប្រសិទ្ធិភាព រដ្ឋធម្មនុញ្ញមានបញ្ចូលបញ្ញត្តិមួយចំនួនអំពីធាតុនៃរចនា-សម្ព័ន្ធ មូលដ្ឋានរបស់រដ្ឋសភា ដែលមានជាអាទិ៍ ប្រធានសភា រដ្ឋបាលសភា និងគណៈកម្មការនានានៅក្នុងសភា ព្រមទាំងបទបញ្ញត្តិស្តីអំពីដំណើរកាការងាររបស់សភា ។

សំរាប់ព័ត៌មានលំអិតអំពីរចនាសម្ព័ន្ធ និងដំណើរការការងាររបស់ខ្លួនដែលមិនបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ រដ្ឋសភាត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងមួយចំនួនខ្លួនឯង ។ នេះមានន័យថា **រដ្ឋសភាគ្រប់គ្រងខ្លួនដោយខ្លួនឯង (ស្វ័យគ្រប់គ្រង= Self-Rule)** ។

[១១] សំរាប់ព័ត៌មានលំអិតអំពីសភាជាតិ សូមមើល: www.cambodian-parliament.org

មាត្រា៩៤ ឃ្លាទី២ CC:
ការរៀបចំ និងការប្រព្រឹត្តិទៅ នៃសភាជាតិ និងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា។

អ្នកនឹងអាចរកព័ត៌មានលំអិតទាំងនេះ នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា[១២] ។

## I) ប្រធានរដ្ឋសភា:

ប្រធានសភា មានមុខងារផ្នែករដ្ឋបាលតែប៉ុណ្ណោះ ត្រូវអនុវត្តនូវឆន្ទៈរបស់រដ្ឋសភា ។ ទោះបីជាខ្លួនគឺជាសមាជិករដ្ឋសភា និងត្រូវបានជ្រើសតាំងដោយសមាជិករដ្ឋសភាភាគច្រើនក៏ដោយ ប្រធានរដ្ឋសភាត្រូវបំពេញភារកិច្ចរបស់ខ្លួនក្នុងលក្ខណៈមួយដែលមិនលំអៀង ហើយជាពិសេស ត្រូវគោរពសិទ្ធិសភារបស់សមាជិកសភាភាគតិច ឬ សមាជិកគណបក្សប្រឆាំង ។

## II) អគ្គលេខាធិការ:

អគ្គលេខាធិការ ដែលត្រូវបានតែងតាំងដោយប្រធានរដ្ឋសភាផងដែរ មានមុខងារផ្នែករដ្ឋបាល ។ អគ្គលេខាធិការរដ្ឋសភា ត្រូវប្រកាន់ភាពអព្យាក្រិត ហើយមិនអាចជាសមាជិកសភា ឬសមាជិកគណបក្សនយោបាយ ឡើយ ។

## III) គណៈកម្មការជំនាញ:

ផ្ទុយទៅវិញ គណៈកម្មការជំនាញនានារបស់រដ្ឋសភា មានអំណាចច្រើនគួរឱ្យកត់សំគាល់ ដើម្បីគ្រប់គ្រងរដ្ឋាភិបាល ។ គណៈកម្មការទាំងនេះ មានអំណាចជាពិសេសក្នុងការអញ្ជើញរដ្ឋមន្ត្រីណាម្នាក់ មកបំភ្លឺនៅចំពោះមុខគណៈកម្មការ នូវកិច្ចការដែលទាក់ទងនឹងក្រសួង និងការទទួលខុសត្រូវរបស់ខ្លួន ។

## IV) សមាជិករដ្ឋសភា:

នៅពេលបច្ចុប្បន្ន **សមាជិករដ្ឋសភា** បំពេញតួនាទីរបស់ខ្លួនដោយមិនសូវសកម្ម ហើយមិនមានជំនឿលើខ្លួនឯងឡើយ គឺគេបំពេញតួនាទីតាមព្រំដែនកំណត់បំផុត ដោយគេត្រូវដាក់កំហិតខ្លួនឯង ។ ភាគច្រើនពួកគេមិនបានលើកឡើងឱ្យសកម្មនូវសំណើពង្រាងច្បាប់ផ្ទាល់ខ្លួនឡើយ ប៉ុន្តែ ក៏រិតតួនាទីរបស់ខ្លួនដោយចាំតែឯកភាពតាមគណបក្សកាន់អំណាចភាគច្រើន លើពង្រាងច្បាប់ដែលដាក់ជូនដោយរដ្ឋាភិបាល ។

នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យផ្សេងៗទៀត ដូចជា ប្រទេសអង់គ្លេស ពង្រាងច្បាប់ភាគច្រើនក៏ត្រូវដាក់ជូនដោយរដ្ឋាភិបាលផងដែរ ។ ប៉ុន្តែផ្ទុយពីតថភាពជាក់ស្តែងនៅក្នុងរដ្ឋសភាកម្ពុជា រដ្ឋសភាអង់គ្លេសមាន

---

[១២] សូមមើល www.cambodian-parliament.org/English/ index.htm (index:¨rules¨)

តួនាទីមិនគ្រាន់តែចាំតែអនុម័ត នូវពង្រាងច្បាប់ដោយសមាជិកសភាភាគច្រើនដែលមកពីគណបក្សកាន់អំណាច ប៉ុណ្ណោះទេ ប៉ុន្តែគេមានតួនាទីដើម្បីបំភ្លឺ និងកែលំអពង្រាងច្បាប់ទាំងនេះ ដោយការពិភាក្សា និងជជែកដេញដោល យ៉ាងចម្រូងចម្រាស់ ទៅលើពង្រាងច្បាប់នៅក្នុងរដ្ឋសភា ដែលក្នុងនោះរួមមានការធ្វើសវនាការជាសាធារណៈ ជាពិសេស ដោយមានការរិះគន់ពីគណបក្សភាគតិច ។

**វប្បធម៌នៃការជជែកដេញដោល និងពិភាក្សា**បែបនេះ មិនទាន់មាននៅក្នុងប្រទេសកម្ពុជានៅឡើយ ។ សវនាការជាសាធារណៈបែបនេះទើបតែកើតមានតែម្តងប៉ុណ្ណោះ និងត្រូវបានរៀបចំយ៉ាងស្ទាក់ស្ទើរដោយសភា ។ ក្រៅពីនេះ សមាជិកសភាភាគច្រើនមិនមែនជាអ្នកច្បាប់ ហើយមិនមានសមត្ថភាពក្នុងការយល់អំពីសេចក្តីលំអិត ផ្នែកទ្រឹស្តីច្បាប់នៃពង្រាងច្បាប់ឱ្យបានពេញលេញឡើយ ។ ព្រោះហេតុដូច្នេះ ពួកគេគួរតែរកជំនួយពី**ជំនួយការសភាដែលជាអ្នកជំនាញ** ។ នៅខែមករា ឆ្នាំ ២០០៣ ច្បាប់មួយត្រូវបានអនុម័តស្តីពី តួនាទី និងភារកិច្ចរបស់មន្ត្រីរាជការ ដែលបម្រើការនៅក្នុងអង្គនីតិបញ្ញត្តិ ។

អាស្រ័យដោយមានតែសម័យប្រជុំសភាតែពីរលើក (មួយលើកមានរយៈពេលបីខែ) ក្នុងមួយឆ្នាំនោះវាមានសារៈសំខាន់ណាស់ដែលត្រូវកត់សំគាល់ថា សមាជិកសភាចំនួន ១/៣ អាចទាមទារឱ្យមាន**សម័យប្រជុំវិសាមញ្ញ** (extraordinary session) នៅពេលណាមួយ (មាត្រា៨៣ II ២ CC ) ។ សម័យប្រជុំនេះគួរតែត្រូវបានធ្វើឡើងឱ្យបានទូលំទូលាយ ពីព្រោះសម័យប្រជុំតែប្រាំមួយខែក្នុងមួយឆ្នាំ មិនគ្រប់គ្រាន់ដើម្បីដោះស្រាយកិច្ចការប្រទេសជាតិទាំងមូលឡើយ ។

# រ ដ្ឋ ស ភ ា

**សមាជិកយ៉ាងហោចណាស់ចំនួន ១២០នាក់ មកពីគ្រប់ខេត្ត ក្រុង នៅទូទាំងប្រទេសកម្ពុជាដែលត្រូវបានជ្រើសរើស ដោយការបោះឆ្នោតជាតិ ជាតំណាងរបស់ប្រជាពលរដ្ឋកម្ពុជា**

( មាត្រា៧៦ I, II និង III និង ៧៧ I CC)

១) ដើម្បីធ្វើច្បាប់ (ដើម្បីអនុវត្តអំណាចនីតិបញ្ញត្តិ) មាត្រា ៩០ I CC ដោយ
- ក) ធ្វើការផ្តួចផ្តើមនូវច្បាប់ថ្មី, មាត្រា ៩១ I CC ឬ
- ខ) ធ្វើវិសោធនកម្មទៅលើច្បាប់ដែលមានស្រាប់ មាត្រា ៩១ II CC

២) ដើម្បីត្រួតពិនិត្យអង្គនីតិប្រតិបត្តិ មាត្រា១២១ CC ដោយ:
- ក) ជ្រើសរើសស្ថាប័នរដ្ឋដទៃទៀត
- ខ) ដេញដោលសួររដ្ឋាភិបាល, មាត្រា៩៩ និងមាត្រា ៩៧ CC និងដោយដាក់ញត្តិបន្ទោសទៅរដ្ឋាភិបាល មាត្រា៩៦ I CC
- គ) បណ្តេញសមាជិករដ្ឋាភិបាល, មាត្រា ៩៨ CC
- ឃ) ដើម្បីដាក់ពាក្យបណ្តឹងចំពោះសមាជិករដ្ឋាភិបាល, មាត្រា ១២៦ II និង III CC
- ង) អនុម័តសេចក្តីសម្រេចរបស់រដ្ឋាភិបាល, មាត្រា៩០ II – V CC

(ថវិកា ការលើកលែងទោស អនុសញ្ញាអន្តរជាតិ ការប្រកាសសង្គ្រាម ឬ ស្ថានភាពមានអាសន្ន មាត្រា ៨៦ I CC)

ជ្រើសរើស

**ប្រធានរដ្ឋសភា** (មាត្រា ៨២ I CC)

(ជ្រើសរើសដោយសមាជិកសភា មាត្រា៨២ I CC)

- ធ្វើជាប្រធាន សម័យប្រជុំ
- ទទួល ពង្រាងច្បាប់ និងសេចក្តីសម្រេចរបស់រដ្ឋសភា
- ចាត់ចែង ទំនាក់ទំនងរវាងរដ្ឋសភា និងប្រទេសដទៃ
- អនុវត្តបទបញ្ជាផ្ទៃក្នុង

តែងតាំង

**អគ្គលេខាធិការដ្ឋាន**

(បទបញ្ជាផ្ទៃក្នុងសភាជំពូកទី៤)

គាត់មិនមែនជាសមាជិកសភា ហើយក៏មិនមែនជាសមាជិកគណបក្សនយោបាយ

- រាល់កិច្ចការរដ្ឋបាលទាំងអស់
- ឯកសារ និងកំណត់ហេតុ
- ទំនាក់ទំនងមកពីក្រៅទាំងអស់ (ឧ. ភ្ញៀវ)

**គណៈកម្មាធិការអចិន្ត្រៃយ៍** (មាត្រា៨៤ CC)

- ចាត់ចែងការងាររបស់រដ្ឋសភាក្នុងអំឡុងពេលចន្លោះសម័យប្រជុំសាមញ្ញទាំងពីរ (សម័យប្រជុំមួយ រយៈពេល៣ខែ)
- រួមមាន ប្រធានរដ្ឋសភា និងអនុប្រធាន និងប្រធាន៩នាក់ នៃគណៈកម្មការទាំង៩

**គណៈកម្មការ** (មាត្រា៩៤ CC)

(គណៈកម្មការចំនួន៩ យោងតាមគោលការណ៍ទី៩ នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា)

- ពិនិត្យមើលពង្រាងច្បាប់ ដែលដាក់ជូនដោយសមាជិកសភា, រដ្ឋាភិបាល ឬព្រឹទ្ធសភា
- ផ្តល់អនុសាសន៍ដល់សភាពេញអង្គ ដើម្បីធ្វើការពិចារណា មិនពិចារណា ឬពិចារណាជាបន្ទាន់ ទៅលើពង្រាងច្បាប់
- គ្រប់គ្រងសកម្មភាពរដ្ឋាភិបាលដែលពាក់ព័ន្ធ

អញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺបញ្ហានៅចំពោះមុខគណៈកម្មការ (មាត្រា៩៧ CC)